**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ០៣៧ ប្រក.កសក

## ប្រកាស
## ស្តីពី
## ការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេសត្រសាស្រ្តនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាព តាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើកែបនៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាន និងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកែបនៃប្រកាសនេះមានមួយ(១)សហគមន៍ព្រៃឈើ ដែលមានផ្ទៃដីមួយកន្លែងសរុបចំនួន៣៦៦ (បីរយហុកសិបប្រាំមួយ )ហិកតា ដូចមានក្នុងផែនទីភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំបិទជិតកំណត់ដោយចំណុចគោលនិងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ ។ ក្នុងករណីមានការចាំបាច់ ព្រំប្រទល់ព្រៃសហគមន៍ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ អាចកែសម្រួលបានតាមការដាក់ស្នើ។

**ប្រការ ៤.-**

ដំណើរការរៀបចំនិងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តកែប ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

ច័ន្ទ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកែប
- ដូចប្រការ ៦
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ ៖

# ផែនទី ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប



ឧបសម្ព័ន្ធ ២ ៖ ភ្ជាប់ប្រកាសលេខ ..០៣៧២...ប្រ.ក.កសក........ចុះថ្ងៃទី ១៨......ខែ កុម្ភៈ.......ឆ្នាំ ២០១៣......

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប

| ល.រ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកា ទីតាំងព្រៃសហគមន៍ | | | | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ចំការបី | ៣៦៦ | 431979 1170403<br>431933 1170197<br>431560 1169494<br>431287 1169049<br>430921 1168491<br>430241 1167578 | 429782 1167000<br>429179 1166634<br>428629 1166914<br>428625 1167229<br>428560 1167473<br>428652 1167628 | 429148 1167731<br>429455 1167907<br>429698 1168282<br>429791 1168385<br>430376 1168603<br>430583 1168852 | 430637 1169098<br>430676 1169682<br>430933 1170257<br>431619 1170352<br>431328 1170685 | ១ | ពងទឹក | ដំណាក់ចង្អើរ | កែប |
| | សរុប | ៣៦៦ | | | | | ១ | ១ | ១ | ១ |

